**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣០
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៤
សាលដីកា
លេខៈ ១៥៧
ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម .......... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក .............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............... ជាចៅក្រម
៦-លោក ................ ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ................ ជាចៅក្រម

ក្រឡាបញ្ជី
-លោកស្រី ................

តំណាងមហាអយ្យការ
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៩៥(ឈ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦ ចុះថ្ងៃទី៣១ ខែឧភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ទគ(ជាម្ចាស់បស្ទឹងសាទុក្ខ) ភេទប្រុសអាយុ៤៩ឆ្នាំ ជាតិខ្មែរ របរកស៊ីជាងទង ទីលំនៅសព្វថ្ងៃភូមិត្រពាំងព្រីង ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

ឪពុកឈ្មោះ បាក់ ឈុន (ស) ម្តាយឈ្មោះ តាន់ ណៃ (ស) ។

និងចុងចម្លើយ

១-ឈ្មោះខរតន(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥២ឆ្នាំជាតិខ្មែរ របរកស៊ីបុគ្គលិកក្រុមហ៊ុនគហទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។
ឪពុកឈ្មោះ ហាក់ខ្លួត (ស) ម្តាយឈ្មោះ ពៅ ហុង (រ )។ មានមេធាវីឈ្មោះ ដួន វាសនា ។

២-ឈ្មោះ ជសរ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥៤ឆ្នាំ ជាតិខ្មែរ របរកស៊ី នាយកក្រុមហ៊ុននគរសំរិទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១០ ផ្លូវលេខ ២៨៥ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោកក្រុងភ្នំពេញ។ ឪពុកឈ្មោះ ភូ មុយស្រេង ម្តាយឈ្មោះ ទិន គីមហួន ។

មានមេធាវីឈ្មោះ ...........ជាតំណាង ។

៣-ឈ្មោះ គហ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៧០ឆ្នាំ ជាតិខ្មែរ របររកស៊ីនាយកក្រុមហ៊ុនគីម ហាប់ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៧ ផ្លូវមុនីរ៉េត សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះ ........... ជាតំណាង ។

<u>**កម្មវត្ថុបណ្តឹង**</u> : ប្តឹងទាមទារប្រាក់

បានឃើញបណ្តឹងសាទុក្ខលេខ២៥៩ ចុះថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០០៣ របស់ឈ្មោះទី គាប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៩៥(ឈ)ចុះថ្ងៃទី ៣០ ខែមិថុនា២០០៣ របស់សាលាឧទ្ធរណ៍លើចំណុច ដែលសាលាឧទ្ធរណ៍មិនសម្រេចលើបណ្តឹងទាមទារប្រាក់បន្ថែមក្នុងប័ណ្ណរបស់ឈ្មោះ ភូ ជាឡាំនិងចំណុចសំណង ជម្ងឺចិត្តនៃសេចក្តីសម្រេច ។

បានឃើញបណ្តឹងសាទុក្ខលេខ២៧៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ របស់មេធាវី...........តំណាងឱ្យឈ្មោះ ជសរ និងឈ្មោះ គីម ហាប់ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៩៥(ឈ)ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើចំណុច នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣០ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូល។

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៨ របស់ដើមចោទឈ្មោះ ទី គា ប្តឹងទារប្រាក់ពីឈ្មោះ ខរតន ជសរ គីម ហាប់ ចំនួន ១៣៣.០០៧ ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន២០០០០ដុល្លាអាមេរិក ដោយអាងហេតុថា ក្រុមហ៊ុននគរសំរិទ្ធ ដែលមានឈ្មោះ ខរតនបានទិញឈើមូលពីពួកអាជីវករខ្លួន ហើយមកដល់ពេលនេះពុំព្រមសងប្រាក់មកអាជីវករបស់ខ្លួនឡើយ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ០៦(យ)ចុះថ្ងៃទី១០ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះទីគាប្តឹងសុំហាមឃាត់ឈ្មោះ ជសរ មិនឱ្យលក់ដូរបញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយទៅឱ្យអ្នកដទៃផ្ទះលេខ១០ ស្ថិតនៅផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ភ្នំពេញទុកជាបណ្តោះអាសន្ននោះទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះ ជសរ មិនឱ្យលក់ដូរ ដូល បញ្ចាំផ្ទេរសិទ្ធិ ឬធ្វើអំណោយទៅអ្នក ដទៃផ្លូវផ្ទះលេខ ១០ស្ថិតនៅផ្លូវលេខ ២៨៥ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ទុកជា បណ្តោះអាសន្ន រង់ចាំតុលាការសម្រេចរឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះទីគា បង់ប្រាក់ប្រដាប់ក្តីចំនួន ២.០០០រៀល ។

៤-បើគូភាគីណាមិនសុខចិត្តនឹងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីដីកាសម្រេចនេះតទៅ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ ០២(ឈ) ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ទគចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩៩ ជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះ ខរតនមិនឱ្យលក់ដូរ ដូល បញ្ចាំផ្ទេរសិទ្ធិ ធ្វើអំណោយទៅឱ្យអ្នកដទៃ និងធ្វើមរតកបន្តទៅឱ្យទាយាទ នូវផ្ទះលេខ ៥ ស្ថិតនៅផ្លូវលេខ ២៨៧ ក្រុម៣៣សង្កាត់បឹងកក់១ខ័ណ្ឌទួលគោកក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចរឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះទគបង់ប្រាក់ប្រដាប់ក្តីចំនួន២.០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់ចំនួន២.០០០ រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-បើគូភាគីណាមិនសុខចិត្តនឹងដីកានេះមានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃគិតចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេចនេះតទៅ ។

បានឃើញពាក្យបណ្តឹងដីកាសម្រេចតាមពាក្យសុំរបស់ឈ្មោះ ទគចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ សុំឃាត់ឈ្មោះ គឹម ហាប់ មិនឱ្យលក់ ដូរ ដូល បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយទៅអ្នកដទៃ និងធ្វើមរតកបន្តនូវផ្ទះលេខ១៧ផ្លូវមុនីរ៉េត សង្កាតវាល់វង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ០៣(ឈ) ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ របស់ពូលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ទគចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះ គឹម ហាប់ មិនឱ្យលក់ដូរ ដូល បញ្ចាំ ផ្ទេរសិទ្ធិធ្វើអំណោយទៅអ្នកដទៃ និងធ្វើមរតកបន្តទៅឱ្យទាយាទ នូវផ្ទះលេខ១៧ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្នរង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះ ទគបង់ប្រាក់ប្រដាប់ក្តីចំនួន២.០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ២.០០០ រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-បើគូភាគីណាមិនសុខចិត្ត នឹងដីកានេះមានសិទ្ធិប្តឹងជំទាស់ក្នុងរយៈពេល១៥ថ្ងៃគិតចាប់ពី ថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេចនេះតទៅ ។

បានឃើញសាលក្រមលេខ ១៥ (ឈ) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៨ របស់ដើមចោទឈ្មោះទគដែលតំណាងឱ្យអាជីវករក្នុងខេត្តស្ទឹងត្រែង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៨ របស់អាជីវករទាំង៩នាក់ ឱ្យឈ្មោះ ទគ តំណាងក្នុងការប្តឹងទាមទារប្រាក់ពីឈ្មោះ ខ្លូត រតនា។ឈ្មោះ គឹមហាប់និងឈ្មោះជសរ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់លិខិតប្រគល់សិទ្ធិចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ គហប្រគល់ឱ្យឈ្មោះ មុំ លុជ្ស ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះ ខរតនតំណាងក្រុមហ៊ុន គីម ហាប់ និង គឹម ហាប់ ដែលជាប្រធានក្រុមហ៊ុន គីម ហាប់ ព្រម ទាំង ជសរ តំណាងក្រុមហ៊ុននគរសំរិទ្ធ រួមគ្នាសងនូវប្រាក់ចំនួន មួយសែន បីម៉ឺនបីពាន់ប្រាំពីរដុល្លាអាមេរិក (១៣៣.០០៧) គ្រប់ចំនួន និងបង់ជម្ងឺចិត្តចំនួន មួយម៉ឺនប្រាំពាន់ដុល្លា អាមេរិក (១៥.០០០) ឱ្យអាជីវករទាំង៩នាក់ នៅខេត្តស្ទឹងត្រែង ដែលតំណាងដោយឈ្មោះ ទគចាប់ពី ថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សម្រេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយ ដែលមានផ្ទះលេខ ១០ ស្ថិតនៅផ្លូវលេខ ២៨៥ សង្កាត់បឹងកក់ទី ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ផ្ទះលេខ៥ ស្ថិតនៅផ្លូវ ២៨៧ ក្រុម៣៣ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ និងផ្ទះលេខ ១៧ ផ្លូវសម្តេច មុនីរ៉េត សង្កាត់វាលវង់ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ដើម្បីលក់ឡាយឡុងជានាសំណងខាង លើ ហើយបើរឹងរូសមិនព្រមសង សម្រេចដាក់គុកបង្ខំរូបកាយ ឈ្មោះខរតនជសរ និង គឹម ហាប់ ចំនួន ៨ខែ តាម មាត្រា ១៣៣ នៃច្បាប់ស្តីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-បង្គាប់ឱ្យឈ្មោះខរតនឈ្មោះជសរនិងឈ្មោះ គឹម ហាប់ បង់ប្រាក់ប្រដាប់ក្តីនិងពន្ធហ្នឹង ១.៨០០រៀល រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះត្រូវ បានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទបានបង់ទុកជាស្រេច កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ ឱ្យឈ្មោះ ខរតនឈ្មោះ ជសរ និងឈ្មោះ គឹម ហាប់ ប្រគល់ប្រាក់ ៧.០០០រៀល ឱ្យទៅដើមចោទវិញ និងឱ្យបង់ពន្ធស មាមាត្រ ១ភាគរយ លើទឹកប្រាក់សរុប ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ។

៦-សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខដើមចោទ ចំពោះមុខតំណាងចុងចម្លើយឈ្មោះ មុំ លុជ្ស និងកំបាំងមុខចុងចម្លើយឈ្មោះ ខរតនឈ្មោះ ជសរ សម្រេចបើកផ្លូវប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបានទទួល ដំណឹងពីសេចក្តីសម្រេចនេះ និងបើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ២ខែ គិតចាប់តាំងពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ជសរ ខ្វត រតនា និងលោកមេធាវី មុំ លុជ្ស ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ១៩៩៩ ប្តឹងមិនសុខចិត្តលើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ទគចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ១៩៩៩ ប្តឹងមិនសុខចិត្តលើសេចក្តី សម្រេច ត្រង់ចំណុចទី ៤ នៃសាលក្រម ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៧២៥ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ១៩៩៩ដែលមានខ្លឹមសារនៃ សេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះ ជសរ,ខ្លូត រតនា និងមេធាវី មុំ លុជ្ស តំណាងឱ្យ គឹម ហាម៍ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះ ទគតំណាងឱ្យ អាជីវករ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-ទទួលពាក្យសុំផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ ជសរ និង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ គឹមហាប់ ខរតនឱ្យទៅលោកមេធាវី ...........ជាណាង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៥(ឈ)ចុះថ្ងៃទី០៨ខែមេសា ឆ្នាំ១៩៩៩ របស់ តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៥-ទទួលយកសំណូមពររបស់ឈ្មោះ សេក សុវណ្ណ ដែលសុំដកពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្លួន នាពេលសវនាការចេញ ដោយឈប់ទាមទារប្រាក់អ្វីទាំងអស់ពីចុងចម្លើយ ។

៦-បដិសេធបណ្តឹង ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ទគចោលជាអសារបង់ ។

៧-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

៨- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខតាម កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ឈ្មោះ ទគចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៩ ប្តឹងមិនសុខចិត្តលើសេចក្តីសម្រេចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការបស់តុលាការកំពូលលេខ ៦៤ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ៤២៥ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៩ របស់ លោក ទគតំណាងអាជីវករ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧២៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៥៩ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែល លោក ទគបានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយ តម្រូវឱ្យលោក ខរតន លោក ជ័យសំរិទ្ធ និងលោក គីម ហាប់ រួបរួមគ្នាសងប្រាក់នេះទៅលោក ទគវិញ ។

៥-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៩៥(ឈ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ ៦៤ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០០ របស់ តុលាការកំពូល ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៥ (ឈ) ចុះថ្ងៃទី០៨ខែមេសាឆ្នាំ១៩៩៩ របស់ តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-បង្គាប់ឱ្យក្រុមហ៊ុន គីម ហាប់ អាហារណ នីហារណ ដែលមានលោក គឹម ហាប់ ជាប្រធានសងប្រាក់ជំពាក់ថ្លៃទិញឈើ ឱ្យទៅដើមចោទឈ្មោះ

ក-ទគចំនួន ២៦.៨៩៥ ដុល្លាអាមេរិក (ពីរម៉ឺនប្រាំមួយពាន់ប្រាំបីរយកៅសិបប្រាំ ដុល្លាអាមេរិក) ។

ខ-ឡៅប ផល្លី ចំនួន ៤៧៣២ ដុល្លាអាមេរិក (បួនពាន់ប្រាំពីរយសាមសិបពីរដុល្លា អាមេរិក ។

សំណូមពរលើសពីនេះ បដិសេធចោល ។ បើគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិ លក់ឡាយឡុង ដើម្បីធានាសំណង ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ២៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាផ្ជាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល និងបង្គាប់ឱ្យចុងចម្លើយ គឺ ក្រុមហ៊ុន គីមហាប់បង់ពន្ធសមាមាត្រ ១ ភាគរយ លើប្រាក់ដែលត្រូវសង ។

៥-សាលដីកនេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៣ ចំពោះមុខតំណាងគូក្តីនិង ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ ចំពោះមុខតំណាងគូក្តីបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ២៥៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ ទគនិងបណ្តឹងសាទុក្ខលេខ ២៧៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ របស់មេធាវី ...........តំណាងឱ្យឈ្មោះ ជសរនិងឈ្មោះ គឹម ហាប់ ស្ថិតនៅក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះ ទគចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៤ ។

បានឃើញ សារណារបស់ឈ្មោះខរតនចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ ។

បានឃើញ សារណារបស់ឈ្មោះ ដូ ចាន់ធីរ៉ាចុះថ្ងៃទី២៧ខែកញ្ញា ឆ្នាំ២០០៥។

បានស្តាប់របាយការណ៍របស់ ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា :

-បណ្តឹងសាទុក្ខលើកទី២ របស់ដើមចោទ និងបណ្តឹងសាទុក្ខរបស់តំណាងចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ។

-សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះខរតន។

បានស្តាប់ចម្លើយរបស់ឈ្មោះទីគា (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ឆ្លើយថា៖

-ខ្លួនសុខចិត្តទទួលយកការសម្រេចរបស់សាលាឧទ្ធរណ៍ តែសុំទាមទារជម្ងឺចិត្ត និងការប្រាក់បន្ថែមទៀត និងសុំទាមទារប្រាក់ឱ្យឈ្មោះ ភូ ជាឡំ ចំនួន ៤១.៨៣៥ ដុល្លាអាមេរិក ។

មេធាវីរបស់ចុងចម្លើយ (ជសរនិងគីមហាប់ធ្វើសេចក្តីសន្និដ្ឋានថា:

-ក្រុមហ៊ុនបានចាត់ឱ្យឈ្មោះ ឡៃ ម៉េង ទៅទិញឈើត្រឹមត្រូវដែលមានការអនុញ្ញាត និងមានការទទួលស្គាល់ពីរុក្ខាប្រមាញ់ ។ តែឈ្មោះនេះឆ្លៀតពេលចុះទៅទិញឈើខុសច្បាប់ពីអាជីវករទាំងនេះ ដើម្បីរកកម្រៃចំណេញខ្លួនឯង មិនមែនទិញឱ្យក្រុមហ៊ុនទេ ។ តែដើម្បីឱ្យរួចខ្លួនឈ្មោះនេះបានក្លែងត្រាបោះ លើវិក័យប័ត្រដើម្បីឱ្យអាជីវករទាំងនោះមកទារលុយពីក្រុមហ៊ុន ។ ម្យ៉ាងទៀត ការប្តឹងទាមទារនេះ ជាការប្តឹងទាមទារផលខុសច្បាប់ខ្លួនសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

មេធាវីរបស់ចុងចម្លើយខរតនធ្វើសេចក្តីសន្និដ្ឋានថា

-ការទិញលក់លើនេះ ជាការទិញលក់រវាងឈ្មោះ ឡៃ ម៉េង ជាមួយអាជីវករទាំងនេះ ថែមទាំងមានហត្ថលេខារបស់ឈ្មោះនេះ តែដើម្បីឱ្យអាជីវករទុកចិត្ត ឈ្មោះនេះបានប្រើត្រាក្លែងក្លាយ និងលិខិតក្លែងក្លាយដើម្បីយកផលចំណេញខ្លួនឯង ដូចនេះពុំមានជាប់ទាក់ទងអ្វីជាមួយកូនក្តីខ្លួនទេ ព្រោះនេះជាការជំពាក់រវាងឈ្មោះ ឡៃ ម៉េង ជាមួយអាជីវករទាំងនោះ ។

-ក្រោយពីបានស្តាប់ របាយការណ៏របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ សារណារបស់លោក ខ្លូត រតនា ចម្លើយរបស់លោកទីគា និងសេចក្តីសន្និដ្ឋានរបស់លោកលោកមេធាវី តំណាងឱ្យលោក ខរតន

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣ របស់លោក ទគនិងបណ្តឹងសាទុក្ខលេខ២៧៥ ចុះថ្ងៃទី១៥ ខែកក្កដាឆ្នាំ២០០៣ របស់លោកមេធាវី ...........ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងតាមមាត្រា ២២៦ នៃច្បាប់ស្តីពី នីតិវិធី ព្រហ្មទណ្ឌដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា មុនសម្រេចសេចក្តីជាថ្មីឡើងវិញ សាលាឧទ្ធរណ៏បានធ្វើការអង្កេតត្រឹមត្រូវ តាមអង្គហេតុនៃរឿងរួចហើយ លើកលែងបណ្តឹងទារជម្ងឺចិត្តរបស់លោក ទគ។ ០

-យល់ឃើញថា នៅដំណាក់កាលនីតិវិធីនៃសាលាឧទ្ធរណ៍ ម្ចាស់បំណុលមួយចំនួន ដែលមានលោក ទគជាតំណាងបានសុំដកបណ្តឹងរបស់ខ្លួនវិញហើយ គឺនៅសល់តែពីរនាក់ប៉ុណ្ណោះ គឺលោក ទី គាដែលមានបំណុលត្រូវទារ

ចំនួន ២៦.៨៩៥ដុល្លា និងលោកឡៅ ផល្លីចំនួន ៤.៧៣២ដុល្លា ប៉ុណ្ណោះ ដែលមានភស្តុតាងច្បាស់លាស់ថា ក្រុមហ៊ុន គីម ហាប់ នៅជំពាក់ប្រាក់ថ្លៃឈើ ដែលបានទិញពីដើមចោទទាំងពីរនាក់នេះ ។

-យល់ឃើញថា ការដែលដើមចោទលោកទីគាប្ដឹងសាទុក្ខសុំឱ្យតុលាការកំពូលសម្រេចជម្ងឺចិត្ត និងសម្រេចបន្ថែមអំពីបណ្ដឹងទារប្រាក់ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៨ ដែលមានកម្មវត្ថុបណ្ដឹងទារប្រាក់របស់ឈ្មោះ ភូ ជាឡំ នោះតុលាការកំពូលអាចពិចារណាបានទេ ពីព្រោះជាបណ្ដឹងទាមទារថ្មីដែលតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណានៅឡើយទេ ។ ប៉ុន្តែសំណងជម្ងឺចិត្ត តុលាការកំពូលអាចទទួលយកមកពិចារណាបាន ។

-យល់ឃើញថា លោក ខរតននិងលោក ឡៃ ម៉េង ពិតជាបានស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ក្រុមហ៊ុន គីម ហាប់ នាពេលដែលឈ្មោះទាំងពីរនេះ ចុះទៅទិញឈើ ហើយការទិញឈើនោះ គឺធ្វើសម្រាប់ក្រុមហ៊ុននេះដែរ ដូច្នេះក្រុមហ៊ុននេះមានកាតព្វកិច្ចសងបំណុលនេះ ដូចការកំណត់នៃមាត្រា ៧៩ ,១២៥ និង ១២៦ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រចស្ដីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

-យល់ឃើញថា ការដែលលោក ខរតនលើកឡើងក្នុងសារណា ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ ក៏ដូចជាការលើកឡើងរបស់លោកមេធាវីចុងចម្លើយថា ការទិញឈើ និងការជំពាក់បំណុលថ្លៃឈើ ពុំពាក់ពន្ធ័ដល់ក្រុមហ៊ុន គីម ហាប់ ទេ គឺបំណុលនេះជាអំពើដោយឡែករបស់ឈ្មោះ ឡៃ ម៉េង ដែលលួចក្លែងលិខិត និងក្លែងត្រា ដែលជាអំពើទុច្ចរិតរបស់លោក ឡៃ ម៉េង និងអាជីវករដែលលួចកាប់ឈើបន្ថែម ពុំមែនជាឈើចាស់ដូចការកំណត់របស់រាជរដ្ឋាភិបាលនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា លោក ខរតនខ្លួនឯងក៏ទទួលស្គាល់ដែរថា ក្នុងឆ្នាំ១៩៩៥ ក្រុមហ៊ុនគីមហាប់ បានបញ្ជូនរូបលោក និងលោក ឡៃ ម៉េង ឱ្យទៅប្រចាំការនៅខេត្តចម្ប៉ាសាក់ ស្រុកប៉ាក់សេ ដូច្នេះបញ្ជាក់ថា លោក ខរតនក្ដី លោក ឡៃ ម៉េង ក្ដី គឺស្ថិតក្រោមការគ្រប់គ្រងរបស់និយោជក គឺក្រុមហ៊ុន គីម ហាប់ ដូច្នេះក្រុមហ៊ុន គីម ហាប់ មានកាតព្វកិច្ចគ្រប់យ៉ាងរបស់និយោជិតរបស់ខ្លួន ម្យ៉ាងទៀតលោកគីមហាប់ខ្លួនឯង ក៏ទទួលស្គាល់ដែរថា ចំពោះបំណុលដែល ត្រូវសងទៅអាជីវករ លោកនឹងសងនៅពេលដែលលោកទារថ្លៃឈើ ពីក្រុមហ៊ុន ដាហ្វីបាន ។ ប៉ុន្តែតាម កិច្ចសន្យាព្រមព្រៀងសហការអាជីវកម្ម ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៤ ក្រុមហ៊ុន គីម ហាប់ និងក្រុមហ៊ុន នគរសំរិទ្ធ បានសហការគ្នាក្នុងការធ្វើអាជីវកម្មនេះ ដូច្នេះការដែលសាលាឧទ្ធរណ៍សម្រេចឱ្យតែក្រុមហ៊ុន គីម ហាប់ ជាប់កាតព្វកិច្ចតែម្នាក់នោះ ជាការពុំត្រឹមត្រូវទេ ដែលតុលាការកំពូលគប្បីពិចារណា និងសម្រេច បន្ថែម ។

-យល់ឃើញថា ការដែលមេធាវីក្នុងចម្លើយ លើកឡើងថា ការលក់ទិញនេះត្រូវទុកជា មោឃៈ ពីព្រោះជាផលនៃអំពើខុសច្បាប់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ការលក់ទិញ បានសម្រេច រួចហើយ ដែលអ្នកទិញមានកាតព្វកិច្ចបង់ប្រាក់ថ្លៃឈើទៅដើមចោទដោយខានពុំបាន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩៥(ឈ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

## ហេតុដូចនេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣ របស់លោក ទគទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ឯគតិច្បាប់ខុសខ្លះ ត្រូវខ្លះ ។

២-ទទួលបណ្ដឹងសាទុក្ខលេខ ២៧៥ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៣ របស់លោកមេធាវី ..........ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

៣-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៩៥(ឈ) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ដោយកែប្រែចំណុចទី៣ ទៅជា បង្គាប់ឱ្យក្រុមហ៊ុន គឹម ហាប់ អាហារណ និហារណ និងក្រុមហ៊ុន នគរសំរិទ្ធ សហការគ្នាសងតាមសមាមាត្រគឺ : ក្រុមហ៊ុន គឹម ហាប់ ត្រូវសង ៨០ភាគរយ និងក្រុមហ៊ុននគរសំរិទ្ធ សង ២០ ភាគរយ លើបំណុល និងជម្ងឺចិត្ត គឺ:

ក-សងទៅឈ្មោះ ទគប្រាក់បំណុលចំនួន ២៦.៨៩៥ដុល្លា និងជម្ងឺចិត្តចំនួន៥០០០ដុល្លា

ខ-សងទៅ ឡៀប ផល្លី បំណុល ចំនួន ៤៧៣២ដុល្លា និងជម្ងឺចិត្តចំនួន៩០០០ដុល្លា

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៣៨.០០០រៀល ដែលដើមចោទបានបង់ គឺ :

-ពន្ធចុះបញ្ជីក្ដីនិងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀលសរុប ១៩.០០០រៀល នៅសល់១៩.០០០រៀល ត្រូវប្រគល់ឱ្យដើមចោទវិញ និងតម្រូវឱ្យចុងចម្លើយសងប្រាក់ចំនួន ៩.៥០០រៀល
ទៅឱ្យដើមចោទ ។

បង្គាប់ឲ្យក្រុមហ៊ុន គឹម ហាប់ និងក្រុមហ៊ុននគរសំរិទ្ធ បង់ពន្ធសមាមាត្រ ១%លើប្រាក់បំណុល និងជម្ងឺចិត្ត ដែលត្រូវសងទៅឱ្យដើមចោទ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០០៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ ។